អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីរម្លឹកៈព័ត៌មានស្តីពីការចូលរួមរបស់សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅក្នុងសវនាការប្រកាសសាលដីកាលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿងប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានប្រកាសថា អង្គជំនុំជម្រះនឹងធ្វើការប្រកាសសាលដីកាលើបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅ **ថ្ងៃសុក្រ ទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១០ ព្រឹក។**

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចអំពីពិរុទ្ធភាពលើ កាំង ហ្គេកអ៊ាវ ហៅ ឌុច អំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ នៅក្នុងសាលក្រមដែលបានប្រកាសនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០។ គាត់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ៣៥ឆ្នាំ។ ជនជាប់ចោទ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ ក្រុម ២ និងក្រុម ៣ បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ សវនាការលើបណ្តឹងសាទុក្ខបានប្រព្រឹត្តទៅនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលពីថ្ងៃទី ២៨ ដល់ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១។

**<u>ព័ត៌មានសម្រាប់អ្នកមកទស្សនានៅតុលាការ</u>**

កន្លែងអង្គុយចំនួន ៤៨២ នៅក្នុងសាលសវនាការសាធារណៈ ត្រូវបានត្រៀមបែងចែកទុកដូចខាងក្រោមៈ

**១. ដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងផ្នែកច្បាប់ ក្នុងសំណុំរឿង ០០១**

កន្លែងអង្គុយចំនួន ១០០ ត្រូវបានត្រៀមទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រួលដោយផ្នែកគាំពារជនរងគ្រោះ និងអង្គការអន្តរការីនានា និងសម្រាប់តំណាងផ្នែកច្បាប់របស់ពួកគាត់។ កន្លែងអង្គុយណាដែលមិនទាន់មានអ្នកអង្គុយ នៅត្រឹមម៉ោង ៩:៤៥ នាទីព្រឹក នឹងត្រូវផ្តល់ជូនទៅឲ្យសាធារណជនទូទៅ។

## ២. មន្ត្រីទូត តំណាងរដ្ឋាភិបាល និងមិត្តរបស់ អ.វ.ត.ក

កន្លែងអង្គុយចំនួន ៥០ ត្រូវបានត្រៀមទុកសម្រាប់ក្រុមនេះ។ សូមចុះឈ្មោះកក់កន្លែងទុកជាមុន តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅ pas@eccc.gov.kh។ **ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅថ្ងៃ សុក្រ ទី ២៧ ខែ មករា ឆ្នាំ ២០១២ វេលាម៉ោង ៤ រសៀល។** កន្លែងអង្គុយណាដែលមិនមានអ្នកអង្គុយនៅត្រឹមម៉ោង ៩:៤៥ នាទី នឹងត្រូវផ្តល់ជូនទៅឲ្យសាធារណជនទូទៅ។

## ៣. តំណាងអង្គការក្រៅរដ្ឋាភិបាល

កន្លែងអង្គុយចំនួន ៥០ ត្រូវបានត្រៀមទុកសម្រាប់អង្គការក្រៅរដ្ឋាភិបាលដែលមានកម្មវិធីពាក់ព័ន្ធនឹង អ.វ.ត.ក។ សូមចុះឈ្មោះកក់កន្លែងទុកជាមុន។ សំណើសុំចុះឈ្មោះកក់កន្លែងអង្គុយទុកជាមុនត្រូវផ្ញើតាមរយៈសារអេឡិចត្រូនិកទៅ pas@eccc.gov.kh ឲ្យបានត្រឹម**ថ្ងៃ សុក្រ ទី ២៧ ខែ មករា ឆ្នាំ ២០១២ វេលាម៉ោង ៤ រសៀល។**

បន្ទាប់ពីថ្ងៃផុតកំណត់សម្រាប់សំណើសុំកន្លែងអង្គុយ និងអាស្រ័យលើចំនួនសរុបនៃសំណើសុំចុះឈ្មោះកក់កន្លែងទុកជាមុន អ.វ.ត.ក នឹងជូនដំណឹងដល់អង្គការក្រៅរដ្ឋាភិបាលនីមួយៗអំពីចំនួនកន្លែងអង្គុយដែលត្រូវបានបម្រុងទុក។ ប្រសិនបើសំណើសុំមានចំនួនលើសពីចំនួនកន្លែងអង្គុយសរុប ដែលត្រូវបានត្រៀមទុក អ.វ.ត.ក នឹងត្រៀមកន្លែងអង្គុយ ដោយយោងតាមសិទ្ធិអាទិភាពខាងក្រោម:

១. បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលមកពីអង្គការអន្តរការី
២. បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធនៅក្នុងកម្មវិធីឃ្លាំមើលតុលាការទៀងទាត់
៣. អង្គការក្រៅរដ្ឋាភិបាលដែលមានវត្តមានទៀងទាត់ នៅក្នុងអំឡុងពេលសវនាការមុនៗ
៤. ផ្សេងៗទៀត

កន្លែងអង្គុយណាដែលមិនមានអ្នកអង្គុយ នៅត្រឹមម៉ោង ៩:៤៥ នាទី នឹងត្រូវប្រគល់ឲ្យសារធារណជនទូទៅ។

## ៤. តំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

កន្លែងអង្គុយចំនួន ២០ នៅក្នុងសាលសវនាការត្រូវបានត្រៀមបម្រុងទុកសម្រាប់តំណាងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន។ សិទ្ធិអាទិភាពនឹងត្រូវបានផ្តល់ឲ្យតំណាងប្រព័ន្ធផ្សព្វផ្សាយផ្នែកបោះពុម្ពផ្សាយ។ សូមចុះឈ្មោះកក់កន្លែងទុកជាមុន។ សំណើសុំចុះឈ្មោះកក់កន្លែងអង្គុយទុកជាមុន ត្រូវផ្ញើតាមរយៈសារអេឡិចត្រូនិកទៅ pas@eccc.gov.kh ឲ្យបានត្រឹម**ថ្ងៃ សុក្រ ទី ២៧ ខែ មករា ឆ្នាំ ២០១២ វេលាម៉ោង ៤ រសៀល។**

តំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលនៅសេសសល់ នឹងត្រូវបានផ្តល់កន្លែងអង្គុយ នៅបន្ទប់សារព័ត៌មាន C105 នៅជាន់ផ្ទាល់ដីនៃអគារតុលាការ។

**៥. ក្រុមនានា**

កន្លែងអង្គុយចំនួន ២១២ នឹងត្រូវបានត្រៀមបម្រុងទុកសម្រាប់ក្រុមនានាដែលត្រូវបានរៀបចំដោយផ្នែកកិច្ចការសាធារណៈរបស់ អ.វ.ត.ក និងអង្គការដៃគូនានា។ កន្លែងអង្គុយណាដែលមិនមានអ្នកអង្គុយនៅត្រឹមម៉ោង ៩:៤៥ នាទី នឹងត្រូវបែងចែកទៅឲ្យសាធារណជនទូទៅ។

**៦. សាធារណជនទូទៅ**

កន្លែងអង្គុយចំនួន ៥០ ត្រូវបានត្រៀមបម្រុងទុកសម្រាប់សាធារណជនទូទៅ ហើយនឹងត្រូវផ្តល់ជូនដោយផ្អែកលើគោលការណ៍ដែលថា អ្នកមកមុន នឹងទទួលបានកន្លែងអង្គុយមុន។

ទ្វាររបងនៅច្រកចូលអ្នកមកទស្សនានៅតុលាការ បើកនៅម៉ោង ៧ ព្រឹក។ អ.វ.ត.ក ណែនាំអ្នកមកទស្សនានៅតុលាការឲ្យមកដល់នៅច្រកទ្វារសន្តិសុខឲ្យបានឆាប់ ដើម្បីទុកពេលវេលាឲ្យបានគ្រប់គ្រាន់សម្រាប់សន្តិសុខធ្វើការត្រួតពិនិត្យ និងចេញសំបុត្រឲ្យ។ ទ្វារចូលទៅកាន់បន្ទប់សវនាការនឹងបិទត្រឹមម៉ោង ៩:៤៥នាទីព្រឹក ឬនៅពេលដែលកន្លែងអង្គុយទាំងអស់នៅក្នុងសាលសវនាការមានមនុស្សអង្គុយពេញ។

សូមធ្វើការណែនាំថា រាល់អ្នកមកទស្សនានៅតុលាការទាំងអស់ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន (ដែលមានបិទរូបថត) នៅច្រកទ្វារចូល។ ពុំអនុញ្ញាតឲ្យអ្នកដែលមានអាយុក្រោម ១៦ឆ្នាំ ចូលទៅកាន់តុលាការទេ រីឯអ្នកដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ ១៨ឆ្នាំ នឹងត្រូវបានអនុញ្ញាតឲ្យចូលទៅកាន់តុលាការបាន លុះត្រាតែមានអាណាព្យាបាលដែលជានីតិជនមកជាមួយ។ អ្នកមកទស្សនានៅតុលាការត្រូវរក្សាសេចក្តីថ្លៃថ្នូរ និងអត្តចរិតសមរម្យជានិច្ច និងត្រូវស្លៀកសម្លៀកបំពាក់សមរម្យ។ ពុំអនុញ្ញាតឲ្យយកទូរសព្ទដៃ កាបូបធំៗ អាហារ ឬភេសជ្ជៈចូលទៅក្នុងសាលសវនាការឡើយ។

អ.វ.ត.ក មានទីតាំងស្ថិតនៅក្នុងសង្កាត់ចោមចៅ រាជធានីភ្នំពេញ ដែលមានចម្ងាយ ១៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៤ ឆ្ពោះទៅកាន់ខេត្តព្រះសីហនុ។ សូមសាធារណជន និងអ្នកសារព័ត៌មានចូលតាមច្រកទ្វារសម្រាប់អ្នកមកទស្សនានៅតុលាការ ដែលស្ថិតនៅប៉ែកខាងកើតនៃបរិវេណតុលាការ។ មានចំណតរថយន្តសម្រាប់អ្នកមកទស្សនាតុលាការ ដោយរថយន្តផ្ទាល់ខ្លួន។

## <u>ការចុះឈ្មោះសុំប័ណ្ណព័ត៌មានសម្រាប់អ្នកសារព័ត៌មាន</u>

អ្នកសារព័ត៌មានដែលមានបំណងចូលរួមតាមដានសវនាការប្រកាសសាលដីកា នៅអ.វ.ត.ក នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ត្រូវតែមានប័ណ្ណសម្រាប់អ្នកសារព័ត៌មាន និងត្រូវចុះឈ្មោះជាមុន។ សូមអនុវត្តតាមនីតិវិធីខាងក្រោម ដើម្បីសុំប័ណ្ណអនុញ្ញាតចូលក្នុងអ.វ.ត.ក។

ក) អ្នកសារព័ត៌មានដែលកំពុងកាន់ប័ណ្ណព័ត៌មានមានសុពលភាពជាផ្លូវការរបស់ អ.វ.ត.ក ត្រូវចុះឈ្មោះនៅផ្នែកកិច្ចការសាធារណៈ តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅ pas@eccc.gov.kh។

ខ) អ្នកសារព័ត៌មានដែលមានប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ.វ.ត.ក ប៉ុន្តែផុតកំណត់ ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណព័ត៌មានសាជាថ្មី <u>ដោយមានចុះហត្ថលេខាផង</u> និងផ្ញើមកជាមួយនឹងសំណើសុំចុះឈ្មោះ តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅ pas@eccc.gov.kh។ សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុតកំណត់ផង។

គ) អ្នកសារព័ត៌មានដែលមិនទាន់មានប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណសារព័ត៌មាន<u>ដោយមានចុះហត្ថលេខា</u> ភ្ជាប់រូបថតទម្រង់ jpg មួយសន្លឹក និងច្បាប់ចម្លងលិខិតឆ្លងដែនមួយច្បាប់ផ្ញើមកជាមួយសំណើសុំចុះឈ្មោះតាមរយៈការផ្ញើសារអេឡិចត្រូនិកទៅ pas@eccc.gov.kh។

ទម្រង់បែបបទសម្រាប់សុំប័ណ្ណព័ត៌មាន អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក:
http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form.doc

អ.វ.ត.ក ត្រៀមបម្រុងកន្លែងអង្គុយចំនួន ២០កន្លែង នៅក្នុងសាលសវនាការសម្រាប់តំណាងសារព័ត៌មាន។ អាទិភាពនឹងត្រូវបានផ្ដល់ជូនអ្នកសារព័ត៌មានខាងផ្នែកបោះពុម្ព។ អ្នកសារព័ត៌មានដទៃទៀតនឹងត្រូវរៀបចំជូនកន្លែងអង្គុយក្នុងបន្ទប់សារព័ត៌មាននៅជាន់ផ្ទាល់ដី។ <u>តំណាងសារព័ត៌មានដែលមានបំណងទទួលបានកន្លែងអង្គុយក្នុងសាលសវនាការត្រូវធ្វើសំណើសុំកន្លែងអង្គុយព្រមគ្នាជាមួយនឹងសំណើសុំចុះឈ្មោះសម្រាប់ការចូលរួមស្ដាប់សវនាការ</u>។

**<u>ថ្ងៃផុតកំណត់សម្រាប់សំណើសុំចុះឈ្មោះរបស់អ្នកព័ត៌មាន និងសំណើសុំប័ណ្ណព័ត៌មាន៖ ថ្ងៃសុក្រ ទី ២៧ ខែ មករា ឆ្នាំ ២០១២ វេលាម៉ោង ៤ រសៀល។</u>**

## <u>សេវាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន</u>

ផ្នែកកិច្ចការសាធារណៈរបស់ អ.វ.ត.ក នឹងផ្ដល់មធ្យោបាយសម្ភារៈនានានៅជាន់ផ្ទាល់ដីនៃអគារតុលាការដើម្បីជួយសម្រួលដល់អ្នកសារព័ត៌មាននៅក្នុងអំឡុងពេលសវនាការ។

នៅក្នុងបន្ទប់ការងារផ្សព្វផ្សាយព័ត៌មាន (C108) មានកន្លែងស្ងប់ស្ងាត់សម្រាប់ធ្វើការ និងមានកុំព្យូទ័រមួយចំនួនដែលមានភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតរួចជាស្រេច សម្រាប់អ្នកសារព័ត៌មានប្រើប្រាស់ តាមគោលការណ៍មកមុនបានមុន។ សូមបញ្ជាក់ថា សេវាអ៊ីនធឺណិតគ្មានខ្សែនៅ អ.វ.ត.ក នៅមានកម្រិតនៅឡើយ ដូច្នេះអ្នកសារព័ត៌មានគួរតែយកម៉ូឌឹម 3G (3G modems) ផ្ទាល់ខ្លួនមកជាមួយ ប្រសិនបើអ្នកសារព័ត៌មានត្រូវការបញ្ជូន ឬទាញយកឯកសារទំហំធំៗ។

នឹងមានផ្តល់ការផ្សាយបន្តផ្ទាល់ជាវីដេអូ និងសំឡេងអំពីដំណើរការសវនាការ នៅក្នុងបន្ទប់សម្រាប់អ្នកសារព័ត៌មាន (C105) ដែលស្ថិតនៅជាន់ផ្ទាល់ដីនៃសាលសវនាការ។ ការផ្សាយបន្តផ្ទាល់ជាភាសាខ្មែរនៅក្នុងបន្ទប់ C109 និងភាសាអង់គ្លេសនៅក្នុងបន្ទប់ C105។

## <u>កន្លែងអង្គុយនៅក្នុងសាលសវនាការសាធារណៈដែលត្រៀមបម្រុងទុកសម្រាប់អ្នកសារព័ត៌មាន</u>

អ្នកសារព័ត៌មានគួរតែមកដល់កន្លែងអង្គុយរបស់ខ្លួនឲ្យបាន ១៥នាទី មុនពេលសវនាការចាប់ផ្តើម។ ពុំអនុញ្ញាតឲ្យយកម៉ាស៊ីនថត កុំព្យូទ័រយួរដៃ ទូរសព្ទដៃ ឬឧបករណ៍ថតសំឡេង ចូលទៅក្នុងសាលសវនាការសាធារណៈឡើយ។

## <u>ការថតរូបភាព</u>

អ.វ.ត.ក នឹងផ្តល់រូបភាពដែលមានគុណភាពច្បាស់ នៅពេលចាប់ផ្តើមសវនាការ។

## <u>ការថតសំឡេង</u>

ការផ្សាយសំឡេងអំពីដំណើរការសវនាការ នឹងត្រូវបានផ្តល់ជូនអ្នកសារព័ត៌មានតាមប្រព័ន្ធ PHONO/XLR។ អ្នកសារព័ត៌មានអាចថតការផ្សាយសំឡេងនេះបាននៅក្នុងបន្ទប់តាមដានព័ត៌មាន (C105) ដោយប្រើឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន ៤៨ (មានឧបករណ៍ភ្ជាប់ចំនួន១៦ សម្រាប់ភាសានីមួយៗ មានខ្មែរ អង់គ្លេស និងបារាំង)។ ការតភ្ជាប់ពីម៉ាស៊ីនថតសំឡេងមួយទៅម៉ាស៊ីនថតសំឡេងមួយទៀត អាចធ្វើទៅបាន ប្រសិនបើអ្នកសារព័ត៌មានមានខ្សែសម្រាប់តភ្ជាប់។ ពុំអនុញ្ញាតឲ្យថតសំឡេងនៅក្នុងសាលសវនាការឡើយ។

## <u>ការថតវីដេអូ</u>

ការផ្សាយវីដេអូអំពីដំណើរការសវនាការ នឹងត្រូវបានផ្តល់ជូនតាមប្រព័ន្ធ BNC (PAL signal)។ អ្នកសារព័ត៌មានអាចថតវីដេអូ នៅក្នុងបន្ទប់តាមដានព័ត៌មាន (C105) ដោយប្រើប្រាស់ឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន៣០ ដែលមាននៅទីនោះ។ ការតភ្ជាប់ពីម៉ាស៊ីនថតវីដេអូមួយ ទៅម៉ាស៊ីនវីដេអូមួយទៀត អាចធ្វើទៅបាន ប្រសិនបើអ្នកសារព័ត៌មានមានខ្សែសម្រាប់តភ្ជាប់។ ពុំអនុញ្ញាតឲ្យថតវីដេអូនៅក្នុងសាលសវនាការឡើយ។

## <u>មធ្យោបាយធ្វើដំណើរសម្រាប់តំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន</u>

អ.វ.ត.ក នឹងផ្តល់ជូននូវមធ្យោបាយធ្វើដំណើរតាមរថយន្តក្រុងដោយឥតគិតថ្លៃសម្រាប់អ្នកសារព័ត៌មាន ណាដែលពុំមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនពីរាជធានីភ្នំពេញ មកកាន់ អ.វ.ត.ក និងមធ្យោបាយធ្វើដំណើរត្រឡប់ទៅវិញ។ រថយន្តក្រុងនឹងធ្វើដំណើរចេញពីមជ្ឈមណ្ឌលព័ត៌មានរបស់ អ.វ.ត.ក ផ្ទះលេខ ៦អា ផ្លូវ ២១ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន នៅវេលា ម៉ោង ៧ ព្រឹក និងនៅចំណុចមុខស្ថានីយ៍រថភ្លើងភ្នំពេញ នៅវេលាម៉ោង ៧:១៥ នាទីព្រឹក នៅថ្ងៃសវនាការ។ សូមចុះឈ្មោះជាមុន តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅ pas@eccc.gov.kh ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរសព្ទដៃ ៖ ៨៥៥(០)១២ ៤៨៨ ០២៣
ទូរសព្ទ ៖ ៨៥៥(០)២៣ ២១៩ ៨៤១ លេខបន្ត ៦១៩៦
សារអេឡិចត្រូនិក ៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃ ៖ ៨៥៥(០)១២ ៤៨៣ ២៨៣
សារអេឡិចត្រូនិក ៖ neth.pheaktra@eccc.gov.kh